ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Feb-2015, 10:48
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម **Chandra Nihal JAYASINGHE**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agniezska KLONOWIECKAMILART**
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម **Florence Ndepele Mwachande MUMBA**
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបតែមួយភាសា ហើយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ

---

**សហព្រះរាជអាជ្ញា**
ជា លាង

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ

Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** ("អង្គជំនុំជម្រះតុលាការកំពូល") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ បានទទួលសំណើមួយដែលបានដាក់ដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ស្នើសុំដាក់សារណាតបរួមរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន តែមួយភាសា ចំណែកឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយឱ្យបានឆាប់រហ័សបំផុត ("សំណើ")[1]។

## ក. **សាវតារ**

២. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១[2] ដោយបានផ្តន្ទាទោស ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះ មានការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានទាំង ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) និងបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[3]។

៣. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រម ដោយ នួន ជា បានស្នើឡើងនូវមូលដ្ឋានបណ្តឹងសាទុក្ខចំនួន ២២៣ និង ខៀវ សំផន បានស្នើឡើងនូវមូលដ្ឋានបណ្តឹងសាទុក្ខចំនួន ១៤៨[4]។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខតែមួយភាសា ឯកសារលេខ F21 ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥។

[2] សាលក្រម សំណុំរឿង ០០២/០១ ឯកសារលេខ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រម")។

[3] សាលក្រម ទំព័រ ៩៧៩។

[4] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ E313/1/1 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313/2/1 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ឯកសារលេខ F3/3 ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។

៤. នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដោយ នួន ជា បានដាក់សារណានេះជាភាសាអង់គ្លេស ហើយ ខៀវ សំផន បានដាក់សារណានេះជាភាសាបារាំង[5] ហើយអង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតឱ្យដាក់ឯកសារបកប្រែជាភាសាខ្មែរតាមក្រោយឱ្យបានឆាប់រហ័សបំផុត[6]។

៥. សហព្រះរាជអាជ្ញា តម្រូវឱ្យដាក់សារណាតបរួមរបស់ខ្លួនក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងសាទុក្ខចុងក្រោយណាមួយរបស់ នួន ជា និង ខៀវ សំផន ជាភាសាខ្មែរ[7]។

## ២. សារណា

៦. សហព្រះរាជអាជ្ញា បានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល ដើម្បីដាក់សារណាតបរួមរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីជាភាសាអង់គ្លេសជាមុនសិន ចំណែកឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឱ្យបានឆាប់រហ័សបំផុត[8]។ ផ្អែកទៅលើព័ត៌មានដែលទទួលបានពីអង្គភាពបកប្រែភាសា ("ITU") សហព្រះរាជអាជ្ញាអះអាងថា ច្បាប់បកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី នឹងត្រូវបញ្ចប់នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥[9]។ ដូច្នេះ យោងតាមសហព្រះរាជអាជ្ញា កាលបរិច្ឆេទសម្រាប់ការដាក់សារណានៃសារណាតបរួមរបស់សហព្រះរាជអាជ្ញា គឺនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។ យោងតាម ITU សហព្រះរាជអាជ្ញាលើកឡើងថា ITU ត្រូវការយ៉ាងហោចណាស់ចំនួន ៤០ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីបញ្ចប់ការបកប្រែសារណាតបរួមទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ពីភាសាអង់គ្លេសទៅជាភាសាខ្មែរ[10]។ ជាលទ្ធផល សំណៅជាភាសាអង់គ្លេសនៃសារណាតប

---

[5] បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ F16 ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤។ *[Corrigé 1] Mémoire d'appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01* ឯកសារ F17 ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (សំណៅដែលបានកែសម្រួលបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤) ("ជារួម សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")។

[6] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ឯកសារលេខ F9 ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ") កថាខណ្ឌ ២៣។

[7] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ កថាខណ្ឌ ២៣។

[8] សំណើសុំ កថាខណ្ឌ ១។

[9] សំណើសុំ កថាខណ្ឌ ៣។

[10] សំណើសុំ កថាខណ្ឌ ៣។

របស់សហព្រះរាជអាជ្ញា នឹងត្រូវរៀបចំបញ្ចប់ និងបញ្ជូនទៅកាន់ ITU នៅត្រឹមថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ២០១៥ ពោលគឺ មុនពេលសហព្រះរាជអាជ្ញា ទទួលបានឯកសារបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[11]។ ដូច្នេះ ភាគីជាតិនៃការិយាល័យសហព្រះរាជអាជ្ញា ពុំអាចរួមចំណែកក្នុងការរៀបចំតាក់តែងសារណាតបនេះបានឡើយ[12]។

៧. លើសពីនេះទៀត សហព្រះរាជអាជ្ញាអះអាងថា ក្រៅពីកិច្ចការរបស់ខ្លួន ទាក់ទិននឹងសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញា ក៏បានចូលរួមយ៉ាងពេញទំហឹងនៅក្នុងកិច្ចការសំណុំរឿង ០០២/០២ និងសំណុំរឿង ០០៣ និង ០០៤ ផងដែរ[13]។ សហព្រះរាជអាជ្ញារំលឹកថា អង្គជំនុំជម្រះតុលាការកំពូល ធ្លាប់បានយល់ព្រមតាមសំណើស្រដៀងគ្នានេះរបស់មេធាវីការពារក្តី ដោយផ្អែកទៅលើទំហំ និងភាពស្មុគស្មាញនៃបញ្ហាខាងផ្លូវច្បាប់នានាលើបណ្តឹងសាទុក្ខ និងពេលវេលាដែលត្រូវការដើម្បីរៀបចំការបកប្រែជាភាសាខ្មែរ[14]។

## គ. ច្បាប់ជាធរមាន

៨. មាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត") ចែងថា "នៅក្នុងកាលៈទេសៈពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក អាចអនុញ្ញាតឲ្យភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែ បន្ទាប់មក ភាគីត្រូវដាក់ឯកសារជាភាសាខ្មែរដែលបានបកប្រែរួចឲ្យបានឆាប់រហ័សបំផុត"។

## ឃ. ការពិភាក្សា

៩. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា វចនាសម្ព័ន្ធ និងអាណត្តិរបស់ អ.វ.ត.ក បានចែងច្បាស់ថា ទាំងភាគីជាតិ និងភាគីអន្តរជាតិ គឺជាសមាសភាពដ៏សំខាន់នៃដំណើរការតុលាការ និងត្រូវពិចារណាអំពីកិច្ចសហការដ៏មានសារៈសំខាន់ ដើម្បីសម្រេចបាននូវគោលដៅកំណត់ដោយច្បាប់របស់ អ.វ.ត.ក។ ត្រង់ចំណុចនេះ ភាគី គ្រប់ពេលទាំងអស់ត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវ

[11] សំណើសុំ កថាខណ្ឌ ៤។

[12] សំណើសុំ កថាខណ្ឌ ៤។

[13] សំណើសុំ កថាខណ្ឌ ៥។

[14] សំណើសុំ កថាខណ្ឌ ៦។

ទូទៅនៃការដាក់ឯកសារជាពីរភាសាក្នុងពេលដំណាលគ្នា។ ការដាក់ឯកសារជាភាសាណាមួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក ត្រូវបានសន្មតថា មានលក្ខណៈផ្លូវការដូចគ្នា ដូចដែលមានបង្កប់ន័យនៅក្នុងមាត្រា ២៦(២) នៃកិច្ចព្រមព្រៀង[15] មាត្រា ៤៥ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក[16] និងមាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្ត។ បន្ថែមទៅលើភាពសមស្របនៃកាលៈទេសៈពិសេស ការអនុញ្ញាតឱ្យដាក់តែភាសាអង់គ្លេស ឬ ភាសាបារាំង គឺចាំបាច់ត្រូវផ្អែកទៅលើការសន្មតថា សមាសភាពជាតិនៃភាគីដាក់ឯកសារ ទទួលបានការជូនដំណឹងច្បាស់លាស់អំពីខ្លឹមសារនៃការដាក់ឯកសារនោះ ហើយពុំបានទទួលការប៉ះពាល់នៅក្នុងការបង្ហាញពីជំហររបស់ខ្លួនឡើយ។

១០. ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា គឺផ្អែកទៅលើសេចក្តីសន្មតចំនួនពីរ។ ទីមួយ សហព្រះរាជអាជ្ញា នឹងត្រូវដាក់សំណៅចុងក្រោយជាភាសាអង់គ្លេសនៃសារណាតបរួមទៅ ITU ដោយមិនចាំបាច់ឱ្យភាគីជាតិនៃការិយាល័យរបស់ខ្លួន មានលទ្ធភាពចូលរួមនៅក្នុងការរៀបចំតាក់តែងសារណាតបនេះឡើយ។ ទីពីរ សហព្រះរាជអាជ្ញា នឹងត្រូវបានរារាំងមិនឱ្យធ្វើការកែសម្រួលបន្ថែមទៀតទៅលើសេចក្តីព្រាងដែលស្នើសុំឱ្យបកប្រែនោះ។ អង្គជំនុំជម្រះតុលាការកំពូល មានបំណងចង់រក្សាទុកនូវសំអាងហេតុខាងលើ។ ទីមួយ អង្គជំនុំជម្រះតុលាការកំពូលរលឹកថា គ្រប់ផ្នែកទាំងអស់របស់ អ.វ.ត.ក ត្រូវសហការ "ដើម្បីយល់ដឹងខ្លឹមសារឯកសារទាំងអស់គ្នា" ដែលបានសរសេរជាភាសាផ្លូវការណាមួយរបស់ អ.វ.ត.ក និងប្រើប្រាស់ធនធានភាសាដែលមាននៅក្នុងការិយាល័យរបស់ខ្លួនឱ្យបានល្អប្រសើរបំផុត ដើម្បីបំពេញការងារឱ្យបានស្របគ្នាជាមួយនឹង ITU ក្នុងការបកប្រែសារណាផ្សេងៗរបស់ខ្លួនជាភាសាខ្មែរ[17]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្មតថា ការរួមចំណែកពីភាគីជាតិនៃការិយាល័យសហព្រះរាជអាជ្ញា នៅតែសំខាន់ បើទោះជា

[15] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ (ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ("កិច្ចព្រមព្រៀង")។

[16] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (**នស/រកម/១០០៤/០០៦**) ("ច្បាប់ស្តីពី អ.វ.ត.ក")។

[17] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/1/2/1 ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៦។

សារណាតបនោះ ត្រូវបានដាក់ជាភាសាអង់គ្លេសមុន ហើយឯកសារបកប្រែជាភាសាខ្មែរដាក់តាមក្រោយក៏ដោយ។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា នៅក្នុងការរៀបចំកិច្ចការរបស់ខ្លួន សហព្រះរាជអាជ្ញាត្រូវពិចារណាទៅលើពេលវេលា ដែលតម្រូវក្នុងការដាក់ឯកសារជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ឬភាសាបារាំង[18]។ ក្នុងការអនុវត្តជាក់ស្តែង សារណាពុំចាំបាច់ត្រូវបានបញ្ចប់ ទាំងស្រុង មុនពេលបញ្ជូនទៅធ្វើការបកប្រែនោះទេ៖ ការបកប្រែត្រូវស្នើឡើងជាផ្នែកៗ ដើម្បីឱ្យ ITU មានលទ្ធភាពពេញលេញ ក្នុងការបកប្រែជាភាសាខ្មែរក្នុងរយៈពេលមួយសមស្រប[19]។

១១. ចំណុចនេះមានន័យថា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សហព្រះរាជអាជ្ញា បានបង្ហាញថា ក្នុងពេលបច្ចុប្បន្ន ខ្លួន មានបន្ទុកការងារច្រើន ទាក់ទងទៅនឹងទំហំ និងភាពស្មុគស្មាញនៃសំណុំរឿងនានា[20] នៅចំពោះមុខនៃ អ.វ.ត.ក ដែលជាកាលៈទេសៈពិសេស ដូចដែលមានចែងនៅក្នុងមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្ត។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ប្រាកដណាស់ នៅក្នុងកាលៈទេសៈស្រដៀងគ្នានេះ អង្គជំនុំជម្រះ បានទទួលយកសំណើរបស់ នួន ជា និង ខៀវ សំផន សុំដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាអង់គ្លេស ឬភាសាបារាំងជាមុនសិន "ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបានបន្ទាប់ពីបកប្រែរួច"[21]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់លើការទទួលខុសត្រូវរបស់ខ្លួនក្នុងការសម្រេចលើបណ្តឹងសាទុក្ខនៅចំពោះមុខ ដែលពុំទាន់បានសម្រេច

[18] សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អៀង សារី សុំដាក់បណ្តឹងសាទុក្ខតែជាភាសាអង់គ្លេសសិន ហើយអត្ថបទជាភាសាខ្មែរនឹងដាក់តាមក្រោម ឯកសារ E254/3/1/1.2 ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។

[19] ស្តីពីបញ្ហាបច្ចុប្បន្នទាក់ទងនឹងលទ្ធភាពរបស់ ITU *សូមមើល* ដីកាសម្រេចលើសំណើរបស់ជនជាប់ចោទ ខៀវ សំផន សុំពង្រឹងអង្គភាពបកប្រែ ឯកសារលេខ F8/1 ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៤។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបង្គាប់ការិយាល័យរដ្ឋបាល ឱ្យពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែជាបន្ទាន់", ឯកសារលេខ E317/1 ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៥។

[20] សំណើសុំ កថាខណ្ឌ ៥។

[21] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ កថាខណ្ឌ ២៣។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ឯកសារ F13/2 ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ (នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ នួន ជា តាមរយៈសារអេឡិចត្រូនិក ត្រូវបានអនុញ្ញាតឱ្យដាក់សារណាតបរបស់គាត់ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាតែមួយភាសាសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ)។

ទៅតាមពេលវេលាសមស្របនៅឡើយ។ នៅពេលដែលសហព្រះរាជអាជ្ញា ដាក់សារណាតបរបស់ខ្លួនបានកាន់តែឆាប់នោះ បើទោះជាដាក់តែភាសាអង់គ្លេសក៏ដោយ ក៏អាចផ្តល់នូវប្រសិទ្ធិភាពនៃកិច្ចដំណើរនេះដែរ។

១២. អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់លើសេចក្តីបញ្ជាក់របស់សហព្រះរាជអាជ្ញាដែលថា សហព្រះរាជអាជ្ញា អាចនឹងដាក់សំណើនាពេលខាងមុខស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រ[22]។ អង្គជំនុំជម្រះតុលាការកំពូល ត្រូវធ្វើការវាយតម្លៃលើសំណើទាំងនេះ នៅពេលណាដែលសំណើទាំងនេះបានដាក់នៅចំពោះមុខ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ទៅលើតម្រូវការចាំបាច់នៃការអនុវត្តកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ឲ្យបានឆាប់រហ័សផងដែរ។

## ខ. <u>**ផ្នែកសម្រេចសេចក្តី**</u>

១៣. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**-សម្រេចទទួលយក**សំណើសុំនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[22] សំណើសុំ កថាខណ្ឌ ៧។